# ជំងឺ COVID-19 ការពិតនៃថ្នាំបង្ការ



## មូលហេតុដែលត្រូវចាក់ថ្នាំបង្ការជំងឺ COVID-19

- ថ្នាំបង្ការកាត់បន្ថយហានិភ័យរបស់អ្នកក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ការត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការស្លាប់ផងដែរ។ ថ្នាំបង្ការក៏ជួយកាត់បន្ថយហានិភ័យរបស់អ្នកក្នុងការមានជំងឺ COVID រយៈពេលវែងផងដែរ។
- អ្នកត្រូវតែទទួលចាក់ថ្នាំបង្ការ **ឱ្យបានគ្រប់ចំនួនដូសដែលបានណែនាំទាំងអស់** ដើម្បីទទួលបានប្រព័ន្ធការពារល្អបំផុត។ ចំណុចនេះរួមមានទាំងការចាក់ **ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (បែបប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent)** ចំនួនមួយដូស សម្រាប់មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ*។ សូមទៅទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (updated booster) របស់អ្នក ប្រសិនបើមានរយៈពេលយ៉ាងហោចណាស់ 2 ខែ ចាប់តាំងពីការចាក់ដូសថ្នាំបង្ការជំងឺ COVID-19 ចុងក្រោយបង្អស់របស់អ្នក។ ការចាក់បែបនេះគឺមិនគិតអំពី ថាតើអ្នកបានទទួលចាក់ដូសជំរុញដើម (បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent) ប៉ុន្មានដូសហើយ និងបានទទួលចាក់ថ្នាំបង្ការប្រភេទណា (មួយ ឬច្រើន) ពីពេលកន្លងមក នោះទេ។
  *មិនមានការអនុញ្ញាតឱ្យចាក់ដូសជំរុញសម្រាប់កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ ហើយដែលបានបញ្ចប់ការចាក់លំដាប់ដំបូងប្រភេទ Pfizer នោះទេ។




## អ្នកដែលអាចទទួលថ្នាំបង្ការបាន

### មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ

- ថ្នាំបង្ការជំងឺ COVID-19 គឺ **មិនគិតថ្លៃ** សម្រាប់មនុស្សគ្រប់រូប - បើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ។
- អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។
- មានការណែនាំឱ្យមនុស្សគ្រប់រូបចាក់ថ្នាំបង្ការ រួមទាំងអ្នកមានផ្ទៃពោះ ឬអ្នកកំពុងបំបៅកូនដោយទឹកដោះ និងអ្នកដែលធ្លាប់មានជំងឺ COVID-19 ផងដែរ។

## ថ្នាំបង្ការជំងឺ COVID-19 ដែលមានការណែនាំឱ្យទទួលចាក់

### ប្រភេទ Moderna

**អាយុចាប់ពី 6 ខែ ឡើងទៅ៖** លំដាប់ដំបូងចំនួន 2 ដូស បូកនឹងដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (updated booster)* ប្រភេទ Pfizer ឬប្រភេទ Moderna ចំនួនមួយដូស

*អាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ អាចទទួលចាក់បានតែដូសជំរុញប្រភេទ Moderna ប៉ុណ្ណោះ

### ប្រភេទ Novavax

**អាយុចាប់ពី 12 ឆ្នាំឡើងទៅ៖** លំដាប់ដំបូងចំនួន 2 ដូស បូកនឹងដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (updated booster) ប្រភេទ Pfizer ឬប្រភេទ Moderna ចំនួនមួយដូស

### ប្រភេទ Pfizer

**អាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ៖** លំដាប់ដំបូងចំនួន 3 ដូស (ដូសទី 3 គឺជាថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញ បែបប្រឆាំងនឹងមេរោគពីរប្រភេទ [updated bivalent dose])
**អាយុចាប់ពី 5 ឆ្នាំឡើងទៅ៖** លំដាប់ដំបូងចំនួន 2 ដូស បូកនឹងដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (updated booster)^ ប្រភេទ Pfizer ឬប្រភេទ Moderna ចំនួនមួយដូស

^ កុមារទាំងឡាយដែលមានអាយុ 5 ឆ្នាំ អាចទទួលចាក់បានតែដូសជំរុញប្រភេទ Pfizer ប៉ុណ្ណោះ

សូមមើលគេហទំព័រ [ph.lacounty.gov/covidvaccineschedules](ph.lacounty.gov/covidvaccineschedules) សម្រាប់ព័ត៌មានបន្ថែម។

ប្រសិនបើអ្នក **មានប្រព័ន្ធភាពស៊ាំចុះខ្សោយ អ្នកអាចនឹងត្រូវការទទួលចាក់ដូសបន្ថែមទៀត** - សូមពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់អ្នក។

ជម្រើសផ្សេងៗទៀត៖ ថ្នាំបង្ការប្រភេទ Johnson & Johnson និង ដូសជំរុញប្រភេទ Novavax អាចផ្តល់ជូនដល់មនុស្សទាំងឡាយដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ នៅក្នុងករណីខ្លះ។






County of Los Angeles Public Health
12-15-22 (Cambodian)



# ជំងឺ COVID-19 ការពិតនៃថ្នាំបង្ការ

## របៀបទទួលថ្នាំបង្ការ

មានទីតាំងចាក់ថ្នាំបង្ការរាប់រយកន្លែងនៅទូទាំងខោនធី LA - ទីតាំងជាច្រើនបើកបម្រើការជូននៅចុងសប្ដាហ៍ និងពេលល្ងាច ហើយមិនចាំបាច់ធ្វើការណាត់ជួបទេ។



ដើម្បីស្វែងរកទីតាំងមួយដែលនៅជិតអ្នក៖

- សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/howtogetvaccinated ឬទូរស័ព្ទទៅលេខ **1-833-540-0473** ចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់។
- អ្នកក៏អាចទូរស័ព្ទទៅលេខ 2-1-1 ឬសាកសួរគ្រូពេទ្យរបស់អ្នក ឬឱសថការី (អ្នកលក់ថ្នាំពេទ្យ) ក្នុងតំបន់របស់អ្នកក៏បាន។
- មានផ្ដល់ការដឹកជញ្ជូនដោយមិនគិតថ្លៃ និងការចាក់ថ្នាំបង្ការនៅតាមផ្ទះផងដែរ។

អនីតិជន (ជនមិនទាន់គ្រប់អាយុ) ត្រូវការការយល់ព្រមពីឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់ដើម្បីទទួលចាក់ថ្នាំបង្ការ។

## តើអាចមានផលប៉ះពាល់អ្វីខ្លះ?

- ផលប៉ះពាល់ទូទៅរួមមាន ការឈឺ ឡើងហើម ឬឡើងក្រហមនៅត្រង់កន្លែងដែលបានចាក់ថ្នាំបង្ការនោះ ឈឺតាមសន្លាក់ឬឈឺសាច់ដុំ ហើមកូនកណ្ដុរ គ្រុនក្ដៅ គ្រុនរងា ឈឺក្បាល និងមានអារម្មណ៍អស់កម្លាំង។ ផលប៉ះពាល់ចំពោះកុមារតូចៗរួមមានដូចជា ឆាប់យំ ឆាប់ខឹង ងងុយគេង និងបាត់បង់ចំណង់អាហារ។
- ផលប៉ះពាល់គឺជាសញ្ញាដែលបង្ហាញថាប្រព័ន្ធភាពស៊ាំរបស់អ្នកកំពុងតែ **បង្កើតប្រព័ន្ធការពារ**។ ផលប៉ះពាល់ទាំងនេះអាចនឹងរំខានដល់អ្នកក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃមួយចំនួន ប៉ុន្តែគួរតែនឹងបាត់ទៅវិញក្នុងរយៈពេលមួយ ឬពីរថ្ងៃ បន្ទាប់ពីបានចាក់ថ្នាំបង្ការរួច។
- ផលប៉ះពាល់បែបធ្ងន់ធ្ងរគឺកម្រនឹងកើតមាន។





## ចុះទាក់ទងនឹងសុវត្ថិភាពវិញ?

- អ្នកមិនអាចកើតជំងឺ COVID-19 ពីថ្នាំបង្ការនោះទេ។ មិនមានថ្នាំបង្ការប្រភេទណាមួយមានផ្ទុកមេរោគដែលអាចបណ្ដាលឱ្យកើតជំងឺ COVID-19 ទេ។
- ថ្នាំបង្ការទាំងឡាយត្រូវបានសាកល្បងទៅលើមនុស្សរាប់ម៉ឺននាក់ រួមទាំងមនុស្សដែលមានពណ៌សម្បុរផ្សេងគ្នា មនុស្សវ័យចំណាស់ និងមនុស្សដែលមានបញ្ហាសុខភាពប្រចាំកាយ ហើយបានរកឃើញថា **មានសុវត្ថិភាព និងមានប្រសិទ្ធិភាព**។
- ចាប់តាំងពីខែធ្នូ ឆ្នាំ 2020 មក **មនុស្សរាប់រយលាននាក់** បានទទួលថ្នាំបង្ការជំងឺ COVID-19 ដោយសុវត្ថិភាព។
- ថ្នាំបង្ការជំងឺ COVID-19 នៅតែបន្តឆ្លងកាត់ **ការត្រួតពិនិត្យផ្នែកសុវត្ថិភាពយ៉ាងល្អិតល្អន់បំផុត** ក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក។
- មិនមានភ័ស្ដុតាងណាមួយដែលបង្ហាញថាថ្នាំបង្ការជំងឺ COVID-19 បណ្ដាលឱ្យមានបញ្ហាមិនអាចមានកូននោះទេ។ ថ្នាំបង្ការទាំងនេះមានសុវត្ថិភាពសម្រាប់អ្នកដែលមានផ្ទៃពោះ និងត្រូវបានណែនាំដោយអ្នកឯកទេសផ្នែកផ្ទៃពោះផងដែរ។



VaccinateLACounty.com

County of Los Angeles Public Health

12-15-22 (Cambodian)